

ឯកសារព័ត៌មាន #៦ - ឆ្នាំ ២០២០

# ការបង្កលក្ខណៈងាយស្រួលនៅមូលដ្ឋានសុខាភិបាល សម្រាប់ការថែទាំសុខភាពប្រកបដោយបរិយាបន្ន

## ហេតុអ្វីបានជាមូលដ្ឋានសុខាភិបាលត្រូវបង្កលក្ខណៈងាយស្រួល ?

- ដើម្បីអនុវត្តតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ(មាត្រា៩) និងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការនៃព្រះរាជាណាចក្រកម្ពុជា (ជំពូក៥ មាត្រា២១)
- ដើម្បីឱ្យជនមានពិការភាពគ្រប់ប្រភេទអាចប្រើប្រាស់សេវាសុខភាពដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃដែរ។

## តើត្រូវបង្កលក្ខណៈងាយស្រួលសម្រាប់នរណា ?

- ដើម្បីធានាបាននូវការទទួលបានសេវាថែទាំសុខភាពសម្រាប់មនុស្សគ្រប់រូបៈ ដូចជាអ្នកដែលមានកម្សោយផ្នែកកាយសម្បទា សតិបញ្ញា និងវិញ្ញាណណាមួយ មិនតែប៉ុណ្ណោះក៏សម្រាប់កុមារ ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ អ្នកដែលមានកម្សោយ ឬអ្នករងរបួសក្នុងរយៈពេលខ្លី ឧទាហរណ៍ ដូចជា បាក់ជើងជាដើម ។ល។

## តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យមូលដ្ឋានសុខាភិបាលមានការបង្កលក្ខណៈងាយស្រួល ?

- ចំពោះមូលដ្ឋានសុខាភិបាលដែលមានស្រាប់ ការធ្វើឱ្យអគារទាំងមូលមានការបង្កលក្ខណៈងាយស្រួលនោះគឺមិនអាចធ្វើទៅបានទេ ប៉ុន្តែវាជាការសំខាន់ណាស់ក្នុងការសម្រួលឲ្យជនមានពិការភាពអាចចូលទៅកាន់ទីធ្លាសាធារណៈបានប្រកបដោយភាពងាយស្រួលដូចជា៖ កន្លែងទទួលភ្ញៀវ បន្ទប់អ្នកជំងឺ ការិយាល័យបុគ្គលិកសុខាភិបាល បន្ទប់រងចាំ និងបង្គន់ ឬបន្ទប់ទឹកជាដើម។

## គោលការណ៍នៃការបង្កលក្ខណៈងាយស្រួល

- គឺជាការមិនកាត់ផ្តាច់ខ្សែសង្វាក់នៃការផ្លាស់ទី ដែលអនុញ្ញាតឱ្យមនុស្សគ្រប់រូបអាចចេញចូលទៅគ្រប់ទីកន្លែងនិងប្រើប្រាស់នូវសេវាកម្មទាំងអស់ តាមរយៈគោលការណ៍ RECU [Reach Enter Circulate Use] ដោយមិនមានឧបសគ្គរាំងទ្បើយ។

អង្គការ HI (ដែលមានឈ្មោះប្រតិបត្តិការថាអង្គការជនពិការអន្តរជាតិ) កំពុងធ្វើការជាដៃគូជាមួយរដ្ឋាភិបាល អង្គការតំណាងជនមានពិការភាព (DPOs) មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRCs) និងគ្រឹះស្ថានសុខាភិបាលផ្សេងៗ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ (NDSP2)។ គម្រោងនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាកម្មប្រកបដោយគុណភាពនិងបរិយាបន្នសម្រាប់ទាំងអស់គ្នារួមទាំងស្ត្រី និងជនមានពិការភាព។ គម្រោងនេះឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី កម្ពុជាដើម្បីសេវាប្រកបដោយសមធម៌និងនិរន្តរភាព (ACCESS)។

# ការបង្កលក្ខណៈងាយស្រួលនៅមូលដ្ឋានសុខាភិបាល

## តើត្រូវធ្វើដូចម្តេច ដើម្បីប្រាកដថាមូលដ្ឋានសុខាភិបាលមានការបង្កលក្ខណៈងាយស្រួល ?

ការធានាថាមូលដ្ឋានសុខាភិបាលបង្កលក្ខណៈងាយស្រួលសម្រាប់ទាំងអស់គ្នានោះ គឺមិនមែនគ្រាន់តែជាការសាងសង់ជម្រាលសម្រាប់រទេះជនមានពិការភាពប៉ុណ្ណោះទេ ប៉ុន្តែសំដៅទៅលើការជួយសម្រួលដល់ការប្រើប្រាស់អគារទាំងមូល នៅគ្រប់ខ្សែសង្វាក់នៃការបម្លាស់ទីទាំងអស់។ ជំហាន RECU អាចជួយយើងក្នុងការកែសម្រួលទាំងនេះបាន៖



- **ការទៅដល់ (Reach)–** មនុស្សគ្រប់រូបគួរតែមានលទ្ធភាពធ្វើដំណើរពីផ្ទះរបស់ពួកគេទៅកាន់មូលដ្ឋានសុខាភិបាល៖ យើងគួរតែគិតអំពីការបង្កលក្ខណៈងាយស្រួលតាមរយៈផ្លូវដើរ ជម្រាលសម្រាប់ទេះរុញ ប្រព័ន្ធដឹកជញ្ជូន ស្លាកសញ្ញា កម្រាលសញ្ញាសម្រាប់ជនមានពិការភាពផ្នែកគំហើញ។ល។
- **ការចូលក្នុង (Enter)–** មនុស្សគ្រប់រូបគួរមានលទ្ធភាពចូលទៅក្នុងអាគារបាន៖យើងគួរតែគិតអំពីការបង្កលក្ខណៈងាយស្រួលតាមរយៈ កាំជណ្តើរ ជម្រាលសម្រាប់រទេះ បង្កាន់ដៃទ្វារចេញចូល ដៃទ្វារ គន្លឹះទ្វារ តុផ្តល់ព័ត៌មាន និងរូបភាពសម្រាប់ទំនាក់ទំនង។ល។
- **ការផ្លាស់ទី (Circulate)–** មនុស្សគ្រប់រូបគួរមានលទ្ធភាពបម្លាស់ទីជុំវិញអគារបាន៖ យើងគួរតែគិតអំពីការបង្កលក្ខណៈងាយស្រួលតាមរយៈផ្លូវដើរខាងក្នុង ច្រកចូលនៅមាត់ទ្វារ ទ្វារខាងក្នុង កន្លែងសម្រាក ជណ្តើរជើង ជណ្តើរយន្ត ស្លាកសញ្ញា ទំហំទីធ្លាជាដើម។ (ឧទាហរណ៍ អ្នកត្រូវការទំហំផ្លាស់ទីយ៉ាងតិចណាស់ ១៥០០ម.ម x ១៥០០ម.ម សម្រាប់ឱ្យអ្នកដែលប្រើរទេះរុញអាចបត់ថយក្រោយ ឬបម្លាស់ទីបាន) ។
- **ការប្រើប្រាស់ (Use)–** មនុស្សគ្រប់រូបគួរមានលទ្ធភាពប្រើប្រាស់សេវាកម្មនិងសម្ភារៈផ្សេងៗនៅក្នុងអគារ៖ យើងគួរតែគិតអំពីការបង្កលក្ខណៈងាយស្រួលតាមរយៈគ្រឿងសង្ហារឹមខាងក្នុង ស្លាកសញ្ញាបង្ហាញទិសដៅ គ្រឿងបរិក្ខារ ប្រភេទនិងកម្ពស់នៃកុងតាក់ភ្លើង រ៉ូប៊ីណេ ចានបង្គន់ ឡាបូលាងដៃ កម្ពស់បង្អួច ។ល។

## ឧទាហរណ៍៖ ការវិភាគបន្ទប់របស់អ្នកជំងឺតាមរយៈជំហាន RECU



រូបភាព ១៖ គំរូនៅក្នុងបន្ទប់អ្នកជំងឺ

- ទ្វារគួរតែមានទំហំធំល្មមសម្រាប់អ្នកដែលប្រើរទេះរុញចេញចូលបាន។ គន្លឹះទ្វារ និងដៃទ្វារគួរតែមានភាពងាយស្រួលក្នុងការប្រើដោយដៃតែម្ខាង ហើយដោយមិនចាំបាច់ត្រូវប្រើម្រាមដៃសម្រាប់អ្នកដែលពិបាកក្នុងការចាប់កាន់វត្ថុផ្សេងៗ (Enter)។
- ធានាថាមានទីធ្លាគ្រប់គ្រាន់នៅក្នុងបន្ទប់ សម្រាប់អ្នកជំងឺផ្ទេរ ឬផ្លាស់ទីពីគ្រែទៅរទេះរុញ (Circulate)។
- ធានាបានថាគ្រឿងបរិក្ខារអនាម័យ (ឡាបូលាងដៃ រ៉ូប៊ីណេ កន្លែងដាក់សាប៊ូ ក្រដាសអនាម័យ ទម្ពក់ខោអាវ ផ្កាឈូកងូតទឹក កញ្ចក់ឆ្លុះ ធុងសម្រាមសម្រាប់ដាក់សំឡីអនាម័យ។ល។ មានភាពងាយស្រួលក្នុងការឈោងយកនិងប្រើប្រាស់ (Use)។
- បង្គន់ ឬបន្ទប់ទឹកគួរតែមានទីធ្លាគ្រប់គ្រាន់ សម្រាប់រទេះរុញហើយគួរតែបំពាក់ដោយធ្នាក់ដៃនៅសងខាងចានបង្គន់ ឬកៅអីអង្គុយងូតទឹក។ (Use)។
- ផ្នែកម្រាល ជញ្ជាំង ទ្វារ បរិក្ខារអនាម័យ ធ្នាក់ដៃ កុងតាក់ភ្លើង និងគ្រឿងបរិក្ខារផ្សេងៗទៀត គួរតែមានភាពងាយស្រួលក្នុងការសម្អាតនិងអាចមើលឃើញបានច្បាស់សម្រាប់អ្នកដែលមានកម្សោយផ្នែកគំហើញ។ (Use)។

**ឯកសារយោង៖** បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព (ឆ្នាំ២០១៨) គួសបញ្ជាក់ពីបទដ្ឋានបច្ចេកទេសក្នុងការធ្វើឱ្យមូលដ្ឋានសុខាភិបាលមានការបង្កលក្ខណៈងាយស្រួល ឬប្រសិនបើអ្នកចង់សាងសង់អាគារថ្មី។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖ dac@dac.org.kh និង contact@cambodia.hi.org